**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៨ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល ដើម្បីពង្រឹងការយល់ដឹងរបស់យុវជនអំពីទិដ្ឋភាពវិជ្ជមាននិងពង្រឹងស្មារតីសាមគ្គីភាពនៅក្នុងសង្គមដែលមានសមាសភាពដូចខាងក្រោម៖



www.pheakdeylaw.com

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| - អគ្គនាយកធនាគារកាណាឌីយ៉ា | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប | អនុប្រធាន |
| - ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា | អនុប្រធាន |
| - អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | អនុប្រធាន |
| - នាយកខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ ១រូប | សមាជិក |
| - តំណាងក្រសួងបរិស្ថាន ១រូប | សមាជិក |
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល ១រូប | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប | សមាជិក |
| - តំណាងសាលារាជធានី ខេត្ត ១រូប | សមាជិក |
| - តំណាងស្ថានីយទូរទស្សន៍បាយ័ន ១រូប | សមាជិក |
| - តំណាងធនាគារកាណាឌីយ៉ា ១រូប | សមាជិក |

សមាសភាពជាក់ស្តែងរបស់គណៈកម្មការនេះ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ២.-**

គណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំផែនការបោះជំរំ
- សម្របសម្រួលការអនុវត្តការងារបោះជំរំយុវជនជាសាកល
- ជំរុញការបោះជំរំជាសាកលឲ្យទូលំទូលាយដល់យុវជនគ្រប់មជ្ឈដ្ឋានទាំងក្នុងនិងក្រៅប្រទេស
- ធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជនដើម្បីរកជំនួយឧបត្ថម្ភនិងផ្លាស់ប្តូរព័ត៌មាន បទពិសោធ និងទស្សនៈរីកចម្រើនដែលទាក់ទងនឹងគោលដៅរួមក្នុងការអភិវឌ្ឍការបោះជំរំយុវជនជាសាកល
- កៀរគរនិងប្រមូលផ្តុំការគាំទ្ររបស់សប្បុរជននិងយុវជនចំពោះការបោះជំរំយុវជនជាសាកល
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារនិងលទ្ធផលនៃការបោះជំរំយុវជនជាសាកល
- ទទួលអនុវត្តភារកិច្ចផ្សេងៗដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣.-**

អនុប្រធាននិងសមាជិកនៃគណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល ដូចមានចែងក្នុងប្រការ១ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។



www.pheakdeylaw.com

ក្នុងករណីចាំបាច់ គណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល មានសិទ្ធិអញ្ជើញអ្នកជំនាញពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ។

**ប្រការ៤ .-**

គណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល មានសិទ្ធិប្រើត្រានិងនិមិត្តសញ្ញារបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៥ .-**

គណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល មានសិទ្ធិបង្កើតអនុគណៈកម្មការនានាតាមការចាំបាច់។

គណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល មានអគ្គនាយកដ្ឋានយុវជនជាលេខាធិការដ្ឋាន។

**ប្រការ៦ .-**

ថវិកាចំណាយសម្រាប់ដំណើរការបោះជំរំយុវជនជាសាកល បានមកពីការរួមចំណែកថវិកាបដិភាគរបស់រដ្ឋនិងចំណូលដែលបានមកពីសប្បុរសជននានា។

**ប្រការ៧ .-**

សេចក្តីសម្រេចលេខ៣១ សសរ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជូរក្តៅ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន(ដូចមានចែងក្នុងប្រការ១) ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០១៧

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com